ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ..០៣៤៤.លទ៦៣../គ.ជ.អ.ប

*រាជធានីភ្នំពេញ, ថ្ងៃទី..១៦. ខែ..មករា ឆ្នាំ២០១៣*

**ជម្រាបជូន**
**ឯកឧត្តមប្រធានសម្ព័ន្ធគាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា**

**<u>កម្មវត្ថុ</u>** ៖ ស្តីពីការបន្ថយបុគ្គលិក និងការគាំទ្រដល់សកម្មភាពមួយចំនួនរបស់អនុកម្មវិធីទី៦ ។
**<u>យោង</u>** ៖ ចំណារឯកភាពលើគោលការណ៍សម្រាប់ការកាត់បន្ថយបុគ្គលិក និងការគាំទ្រដល់សកម្មភាពមួយចំនួននៃអនុកម្មវិធីទី៦ របស់ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ ដោយផ្អែកទៅតាមស្ថានភាពធ្លាក់ចុះនៃការគាំទ្រមូលនិធិរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១៣ ដល់ផអ៣ និងផែនការគាំទ្រដល់អនុកម្មវិធី៦ ដោយគម្រោង UNDP/ACCESS តម្រូវឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប មានវិធានការកាត់បន្ថយនូវបុគ្គលិក និងកាត់បន្ថយការគាំទ្រសកម្មភាពចំនួនដោយសារមុខតំណែងរបស់បុគ្គលិក និងសកម្មភាពទាំងនេះនឹងត្រូវគាំទ្រដោយគម្រោង UNDP/ACCESS និងដើម្បីលើកកម្ពស់សុខដុមនីយកម្ម និងប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិគាំទ្រដោយដៃគូអភិវឌ្ឍន៍រួមមានដូចខាងក្រោម ៖

**I. ការកាត់បន្ថយការគាំទ្រសកម្មភាព**

- កាត់បន្ថយការគាំទ្រសកម្មភាពនានាក្នុងឆ្នាំ២០១៣ដែលពាក់ព័ន្ធនឹងការកែសម្រួល និងការបង្កើតសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (ថ្នាក់មូលដ្ឋាន) ការអភិវឌ្ឍសមត្ថភាព និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត ព្រោះសកម្មភាពទាំងនេះនឹងគាំទ្រដោយគម្រោង UNDP/ACCESS ។

**II. ការកាត់បន្ថយបុគ្គលិកមួយចំនួន**

កាត់បន្ថយមុខតំណែងបុគ្គលិកមួយចំនួនរបស់អនុកម្មវិធីទី៦ ដែលកំពុងគាំទ្រដោយមូលនិធិកញ្ចប់រួម ព្រោះមុខតំណែងទាំងនេះមានលក្ខណៈដូចគ្នា និង/ឬស្រដៀងគ្នាទៅនឹងមុខតំណែងដែលនឹងគាំទ្រដោយគម្រោង UNDP/ACCESS ៖

- ផ្អាកការជ្រើសរើសមុខតំណែងទីប្រឹក្សាគោលនយោបាយ (National Policy Advisor) ជាបណ្តោះអាសន្ន
- មន្ត្រីក្របខ័ណ្ឌច្បាប់ (Legal Framework Officer) នឹងផ្តល់ជូនកិច្ចសន្យាតែ៣ខែ
- មន្ត្រីរដ្ឋបាល (Administration Officer) នឹងផ្តល់ជូនកិច្ចសន្យាតែ៣ខែ
- មន្ត្រីព័ត៌មាន (Information Officer) នឹងផ្តល់ជូនកិច្ចសន្យាតែ៣ខែ
- មន្ត្រីគណនី និងថវិកា (Accounting and Budgeting Officer) នឹងផ្តល់ជូនកិច្ចសន្យាតែ៣ខែ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តារៀបចំ និងចាត់ចែងប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមស្មារតីនៃលិខិតនេះ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
អនុប្រធាន

**ចាន់ ចំរើន**

**ចម្លងជូន ៖**

- គ្រប់អង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប
- គម្រោង UNDP/ACCESS
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សម្ព័ន្ធភាពជាតិឃុំ សង្កាត់**
**នៃព្រះរាជាណាចក្រកម្ពុជា**

លេខ ០០៣/១៤ ស.ជ.ឃ.ស

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣

## សូមគោរពជូន

## ឯកឧត្តមប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

**<u>កម្មវត្ថុ</u>៖** ស្តីពីការបន្ថយបុគ្គលិក និងការគាំទ្រដល់សកម្មភាពមួយចំនួនរបស់អនុកម្មវិធីទី៦។

**<u>យោង</u>៖** លិខិតលេខ០៣៤ សជណ/គជអប ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានទទួលលិខិតជូនដំណឹងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការបន្ថយបុគ្គលិក និងការគាំទ្រដល់សកម្មភាពមួយចំនួនរបស់អនុកម្មវិធីទី៦។ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ សូមធ្វើការបញ្ជាក់ និងមានសំណូមពរមួយចំនួនជូនលេខាធិការដ្ឋាន គ.ជ.អ.ប ដូចខាងក្រោម៖

I. ការកាត់បន្ថយការគាំទ្រសកម្មភាព

តាមស្មារតីអនុកម្មវិធីទី ៦ នៃផអ៣ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ មានតួនាទីសម្របសម្រួលនៅក្នុងដំណើរការបង្កើតសមាគមរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ពោលគឺសមាគមក្រុមប្រឹក្សារាជធានី ខេត្ត និង សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយមានការគាំទ្រថវិកា និងបច្ចេកទេសពីលេខាធិការដ្ឋាន គ.ជ.អ.ប។ តាមឯកសារគម្រោង UNDP/ACCESS គម្រោងនេះ មានតួនាទីពង្រឹងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលត្រូវបានបង្កើតឡើងក្រោមការគាំទ្ររបស់ ផ.អ.៣។ ផ្អែកតាមខ្លឹមសារនៃលិខិតរបស់ គ.ជ.អ.ប ខាងលើ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នឹងជួបការលំបាកក្នុងការស្វែងរកថវិកាសម្របសម្រួលដំណើរការបង្កើតសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

II. ការកាត់បន្ថយបុគ្គលិកមួយចំនួន

លិខិតរបស់ គ.ជ.អ.ប បានលើកឡើងអំពីការផ្អាកការជ្រើសរើសមុខតំណែងទីប្រឹក្សាគោលនយោបាយ និងបន្តកិច្ចសន្យារយៈពេលបីខែចំពោះមន្ត្រីក្របខ័ណ្ឌច្បាប់ មន្ត្រីរដ្ឋបាល មន្ត្រីព័ត៌មាន និងមន្ត្រីគណនី និងថវិកា។ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ស្នើសុំយ៉ាងទទូចឲ្យលេខាធិការដ្ឋាន គ.ជ.អ.ប បន្តកិច្ចសន្យាជាធម្មតាសម្រាប់មន្ត្រីរដ្ឋបាល និង

ស្ថិតក្នុងបរិវេណព្រឹទ្ធសភា មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ(+៨៥៥) ២៣ ៧២៦ ២៥៤ អ៊ីមែល: darapok@ezecom.com.kh Website: www.nlcs.org.kh

មន្ត្រីគណនី និងថវិកា ដោយសារមន្ត្រីទាំងពីររូបនេះ បានទទួលការបណ្តុះបណ្តាល និងការកសាងសមត្ថភាពជាច្រើនពី គ.ជ.អ.ប ក្នុងរយៈកាលកន្លងមក។ ដូច្នេះ មន្ត្រីទាំងពីររូបនេះ មានចំណេះដឹងច្បាស់លាស់អំពីនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប។ ការប្រើប្រាស់បុគ្គលិកក្រោមគម្រោងផ្សេងសម្រាប់បំរើឲ្យការងារទាក់ទងនឹងនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប នឹងត្រូវចំណាយពេលច្រើនសម្រាប់បណ្តុះបណ្តាលបុគ្គលិកឡើងវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាពិនិត្យលទ្ធភាពបន្តកិច្ចសន្យាដល់មន្ត្រី**ទាំង ពីររូប** ខាងលើ ដោយអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធាន**

**សយ គុសល**

សក់_សេដ្ឋា

ចាន់ ចំរើន

ចំលងជូន៖

- គម្រោង UNDP/ACCESS
- ឯកសារ-កាលប្បវត្តិ